ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 26-Nov-2012, 14:23
CMS/CFO: Sann Rada

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour Suprême

សំណុំរឿងលេខ: ០០២/១៩-កញ្ញា-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក(១៧)
Case File/Dossier N°. 002/19-09-2007-ECCC-TC/SC(17)

នៅចំពោះមុខ: ចៅក្រម គង់ ស្រ៊ីម ប្រធាន
ចៅក្រម Chandra Nihal JAYASINGHE
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម Agnieszka KLONOWIECKA-MILART
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម Florence Ndepele Mwachande MUMBA
ចៅក្រម យ៉ា ណារិន

កាលបរិច្ឆេទ: ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២
ភាសា: ខ្មែរ/អង់គ្លេស
ចំណាត់ថ្នាក់ឯកសារ: សាធារណៈ

# សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា "ប្រឆាំងនឹងការបដិសេធជាក់ស្តែងដោយមិនបានសម្រេចលើសំណើសុំឱ្យធ្វើចំណាត់ការជាបន្ទាន់តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង"

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY

**ជនជាប់ចោទ**
នួន ជា

**<u>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**

ពេជ អង្គ

Elisabeth SIMONNEAU FORT

**<u>មេធាវីជនជាប់ចោទ</u>**

សុន អារុន

Victor KOPPE

Michiel PESTMAN

1. **អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសម្រាប់កាត់ទោសឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យពីចន្លោះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ("អង្គជំនុំជម្រះតុលាការកំពូល" និង "អ.វ.ត.ក",) បានទទួលបណ្តឹងសាទុក្ខ"បណ្តឹងសាទុក្ខប្រឆាំងនឹងការបដិសេធជាក់ស្តែងដោយមិនបានសម្រេចលើសំណើសុំឱ្យមានចំណាត់ការបន្ទាន់តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង" ដែលត្រូវបានដាក់ដោយមេធាវីការពារក្តី **នួន ជា** ("មេធាវីការពារក្តី") នៅថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១២ ("បណ្តឹងសាទុក្ខ")[1]។

2. នៅថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១២ មេធាវីការពារក្តី បានដាក់"សំណើសុំឱ្យមានចំណាត់ការបន្ទាន់តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង" នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង("សំណើសុំ")[2]។ សំណើសុំនេះបានដាក់ជាការឆ្លើយតបទៅនឹងការលាឈប់ពីមុខតំណែងរបស់សហចៅក្រមបម្រុងអន្តរជាតិ Laurent KASPER-ANSERMET, ដែលមេធាវីការពារក្តីបានលើកឡើងនោះ គឺជា "ភស្តុតាងបញ្ជាក់ច្បាស់លាស់ថា ពុំមានសមាជិកកម្ពុជារបស់ អ.វ.ត.ក អាចអនុវត្តន៍ប្រឆាំងនឹងរបៀបវារៈផ្ទៃកតុលាការរបស់រាជរដ្ឋាភិបាលកម្ពុជាឡើយ"[3]។ ដូចនេះ មេធាវីការពារក្តីស្នើសុំការទទួលស្គាល់នូវការរងព្យសនកម្មពីលិខិតសុំលាលែងពីមុខតំណែងរបស់ចៅក្រម KASPER-ANSERMET, ដែលស្នើឱ្យមានការស្រាវជ្រាវឱ្យបានពេញលេញចំពោះអានុភាពនៃការជ្រៀតជ្រែករបស់រដ្ឋាភិបាលលើកិច្ចការក្នុងសំណុំរឿង ០០២ និងការផ្អាកនីតិវិធីដោយរង់ចាំលទ្ធផលនៃការស៊ើបអង្កេតនេះ[4]។ សហព្រះរាជអាជ្ញា ជំទាស់នៅនឹងសំណើសុំនេះទាំងមូល[5]។

3. បន្ទាប់ពីរង់ចាំនូវសេចក្តីសម្រេចអស់រយៈពេលជិតប្រាំមួយខែមក មេធាវីការពារក្តីបានដាក់បណ្តឹងសាទុក្ខនេះ ដោយស្របតាមវិធាន ១០៤(៤)(ឃ) នៃវិធានផ្ទៃក្នុង[6] ដោយលើកឡើងថា ការខកខានរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការដោះស្រាយលើសំណើក្នុងពេលវេលាសមហេតុផលនោះ គឺជាការបដិសេធជាក់ស្តែងដោយ

---

[1] ឯកសារលេខ E189/2/1។

[2] ឯកសារលេខ E189។

[3] សំណើសុំ កថាខណ្ឌ ១៩។ *សូមមើលផងដែរ* សំណើសុំ កថាខណ្ឌ ១, ៦ ដល់ ១១ និង ២០។

[4] សំណើសុំ កថាខណ្ឌ ២៨ ។ សូមមើលផងដែរ សំណើសុំ កថាខណ្ឌ ១៦ដល់១៨, ២១ដល់១៧។

[5] សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើសុំរបស់ នួន ជា ឱ្យមាបចំណាត់ការបន្ទាន់តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ឯកសារលេខ E189/1, ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១២។

[6] វិធានផ្ទៃក្នុងរបស់អវតក វិសោធនកម្មលើកទី ៨ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១១ ("វិធានផ្ទៃក្នុង")។ វិធាន ១០៤(៤)(ឃ) នៃវិធានផ្ទៃក្នុងចែងថា "សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការជ្រៀងជ្រែកក្នុងកិច្ចការរដ្ឋបាលតុលាការ តាមវិធាន ៣៥(៦) [តម្រូវឱ្យធ្វើបណ្តឹងសាទុក្ខភ្លាមៗ]"។

មិនបានសម្រេចលើសំណើសុំ[7]។ មេធាវីការពារក្តីបន្តអះអាងទៀតថា ការបដិសេធដាក់ស្តែងដោយមិនបានសម្រេចលើសំណើសុំដោយគ្មានហេតុផលនេះ គឺជាកំហុសអង្គច្បាប់ និងជាការរំលោភនូវឆន្ទានុសិទ្ធិតាមវិធាន ១០៤(១) នៃវិធានផ្ទៃក្នុង[8]។ ហេតុនេះ មេធាវីការពារក្តីស្នើសុំអង្គជំនុំជម្រះតុលាការកំពូល "បញ្ជាក់នូវយុត្តាធិការលើបណ្តឹងសាទុក្ខ ដើម្បីធានាបានថា ការលើកឡើងនៅក្នុងសំណើសុំនេះ ត្រូវបានដោះស្រាយឱ្យបានឆាប់រហ័ស"[9]។

4. ជាការឆ្លើយតប សហព្រះរាជអាជ្ញាពុំមានការជំទាស់ទៅនឹងភាពអាចទទួលយកបានតាមទម្រង់នៃបណ្តឹងសាទុក្ខនេះទេ ប៉ុន្តែ រក្សានូវការជំទាស់ពីដំបូងរបស់ខ្លួនទៅនឹងសំណើសុំនេះ[10]។ សហព្រះរាជអាជ្ញា បន្ថែមទៀតថា គោលគំនិតនៃការបដិសេធដាក់ស្តែងដោយមិនបានសម្រេចលើសំណើសុំនេះ មានលក្ខណៈថ្មីប្លែកនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ហេតុដូច្នេះ សហព្រះរាជអាជ្ញាធ្វើការសង្កេតលើបញ្ហានេះវិញ[11]។

5. នៅថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចមានសំអាងហេតុជាលាយលក្ខណ៍អក្សរដោយបានបដិសេធសំណើនេះចោលទាំងស្រុង[12]។ ហេតុនេះ បញ្ហាដែលថា តើសំណើសុំនេះត្រូវបានបដិសេធ*យ៉ាងដាក់ស្តែងដោយមិនបានសម្រេច* ដែរ ឬយ៉ាងណានោះ ពុំសមហេតុផលក្នុងការពិចារណាឡើយ។ ដោយបានធ្វើការពិចារណាទៅលើការលំបាកនាពេលបច្ចុប្បន្ន ដែលមាននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងអំពីបន្ទុកការងារដែលខ្លួនត្រូវបំពេញ[13] តែទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះតុលាការ

---

[7] បណ្តឹងសាទុក្ខ កថាខណ្ឌ ១ ដល់ ៤ និង ៦។

[8] បណ្តឹងសាទុក្ខ កថាខណ្ឌ ៦។

[9] បណ្តឹងសាទុក្ខ កថាខណ្ឌ ៥។ *សូមមើលផងដែរ* បណ្តឹងសាទុក្ខ កថាខណ្ឌ ៧។

[10] សារណាតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងសាទុក្ខរបស់ នួន ជា "ប្រឆាំងនឹងការបដិសេធដាក់ស្តែងដោយមិនបានសម្រេចលើសំណើសុំឱ្យចាត់វិធានការបន្ទាន់តាមវិធាន ៣៥", ឯកសារលេខ E189/2/2, ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១២ ("សារណាតប"), កថាខណ្ឌ ៣ និង ១៣។

[11] សារណាតប កថាខណ្ឌ ៣ ដល់១២។

[12] សេចក្តីសម្រេចលើសំណើសុំចំណាត់ការបន្ទាន់តាមវិធាន ៣៥នៃវិធានផ្ទៃក្នុង ឯកសារលេខ E189/3, ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ និងត្រូវបានដាក់នៅថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២។

[13] សូមមើល ប្រតិចារិក (KH), ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២, **ឯកសារលេខ** E1/137.1, ទំព័រ ៤១ ដល់ ៤៣ ("អង្គជំនុំជម្រះសាលាដំបូង បានទទួលដំណឹងពីផ្នែករដ្ឋបាលរបស់[ជំនួយការអង្គការសហប្រជាជាតិចំពោះការជំនុំជម្រះក្តីខ្មែរក្រហម("UNAKRT")] ថា ដោយសារតែបញ្ហាហិរញ្ញវត្ថុ អង្គជំនុំជម្រះសាលាដំបូង មិនអាចជ្រើសរើសបុគ្គលិកផ្នែកច្បាប់អន្តរជាតិសំខាន់ៗមួយចំនួន ក៏ដូចជាបុគ្គលិកដទៃទៀតបានទេ។ បញ្ហានេះបណ្តាលឱ្យមានការកាត់បន្ថយបុគ្គលិកពាក់កណ្តាលចំនួនបុគ្គលិកដែលបានកំណត់នៅក្នុងតារាងជ្រើសរើសបុគ្គលិក។ កាលពីបីខែកន្លងទៅ អង្គជំនុំជម្រះបានផ្តល់យោបល់ទៅដល់អង្គការសហប្រជាជាតិដែលពាក់ព័ន្ធជាថ្មីម្តងទៀត និងផ្នែករដ្ឋបាលតុលាការអង្គការសហប្រជាជាតិ អំពីការលំបាកដែលខ្លួនកំពុងជួបប្រទះ ជាយថាហេតុ។ ជាការឆ្លើយតប មានការធានា

កំពូលកត់សម្គាល់ឃើញដោយក្តីបារម្ភអំពីការពន្យារពេលរបស់អង្គជំនុំជម្រះសាលាដំបូង រយៈពេលប្រាំមួយខែក្នុងការចេញសេចក្តីសម្រេចពេញលេញលើសំណើសុំនេះ ហើយអង្គជំនុំជម្រះបានពិចារណាឃើញថា ទាក់ទងបញ្ហានេះ ការទាមទាររបស់មេធាវីការពារបានផ្តល់នូវអង្គសេចក្តីខ្លះៗផងដែរ។

6. យោងតាមសំអាងហេតុដូចបានលើកឡើងខាងលើ **អង្គជំនុំជម្រះតុលាការកំពូល៖ ប្រកាសបដិសេធ** បណ្តឹងសាទុក្ខចោលជាអាសាបង់ ដោយមិនមានការប៉ះពាល់ដល់សិទ្ធិរបស់មេធាវីការពារក្តីក្នុងការដាក់បណ្តឹងសាទុក្ខបន្តទៀត ដោយអនុលោមតាមវិធាន ១០៤(៤)(ឃ) នៃវិធានផ្ទៃក្នុង ទៅលើមូលដ្ឋាននៃសំអាងហេតុរបស់អង្គជំនុំជម្រះជាលាយលក្ខណ៍អក្សរ ចំពោះការបដិសេធលើសំណើនេះ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រីម**

---

អះអាងថា បញ្ហាខ្វះបុគ្គលិក នឹងត្រូវបានដោះស្រាយ ប៉ុន្តែ រហូតមកដល់ពេលនេះ ពុំទទួលបាននូវការដោះស្រាយណាមួយឡើង។ ហេតុនេះ អង្គជំនុំជម្រះសាលាដំបូង បញ្ជាក់នាពេលថ្មីៗនេះថា នៅពេលដែលពុំមានបុគ្គលិកគ្រប់គ្រាន់ក្នុងការជួយដល់ការងារអង្គជំនុំជម្រះទេនោះ ខ្លួនមិនអាចបន្តដំណើរការសម្រាប់រយៈពេលបួនថ្ងៃក្នុងមួយសប្តាហ៍បានទេ ហើយថា ជាការសោកស្តាយផងដែរថា បញ្ហានេះនឹងនាំឱ្យមានការពន្យារពេលក្នុងសំណុំរឿង ០០២/០១ បន្តទៀត។ ទោះបីជាការផ្តល់យោបល់នេះត្រូវបានធ្វើឡើងដោយអង្គជំនុំជម្រះកាលពីពីរសប្តាហ៍កន្លងទៅក៏ដោយ ក៏ពុំមានការអះអាងណាមួយថា បញ្ហាខ្វះបុគ្គលិកនេះនឹងត្រូវដោះស្រាយឡើយ។ អាស្រ័យហេតុនេះ និងដើម្បីជូនដំណឹងដល់ភាគី និងសាធារណជនឱ្យបានឆាប់នោះ អង្គជំនុំជម្រះនឹងបន្តដំណើរការរបស់ខ្លួនចាប់ពីថ្ងៃ ច័ន្ទ ដល់ថ្ងៃ ពុធ តែប៉ុណ្ណោះ ដោយចាប់ផ្តើមពីថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ តទៅ")។